ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN

ឆ្នាំទី ០១ លេខ ០៥ ខែ កញ្ញា ឆ្នាំ ២០១៥ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION



# បទពិសោធន៍ជោគជ័យកសិករជ័យលាភី សឿង ធីរៈ លើការកែច្នៃចំណីសត្វជ្រូក ឱ្យមានតម្លៃថោក គុណភាពល្អ

**ប្រវត្តិសង្ខេប**

លោក **សឿង ធីរៈ** ជាប្រធានសមាគមផលិតចំណីសត្វ នៅភូមិកន្ទ្រាមខ្លែង ឃុំជំរះពេន ស្រុកសំរោង ខេត្ត តាកែវ។

គោលបំណង ដែលលោកសម្រេចចិត្ត ចាប់យកការងារនេះ គឺចង់បង្កើនកម្រិតជីវភាពគ្រួសារ តាមរយៈការចិញ្ចឹមសត្វ កាត់បន្ថយការចំណាយថ្លៃដើម ទៅលើការទិញចំណីសម្រេច ដើម្បីបំពេញតម្រូវការ និងការអភិវឌ្ឍសហគមន៍ឱ្យ មានការរីកចម្រើន។

**ប្រវត្តិនៃការកកើតសហគមន៍ផលិតចំណីសត្វ**

សមាគមន៍នេះ ចាប់ផ្តើមដំណើរការពីថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩ សមាគមនេះ បានកកើតឡើងដោយមានការសម្របសម្រួលពី គម្រោង អេម អេស អេម អ៊ី កម្ពុជា ដោយសហការ ជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាល ខេត្តតាកែវ ។

មានសមាជិកចំនួន ១១នាក់បានចូលថវិកាគ្នាក្នុង១នាក់ចំនួន ១០០.០០០រៀលដោយស្ម័គ្រចិត្ត។

**ការរៀបចំសកម្មភាពក្នុងសហគមន៍**

- ចង់ក្រងក្រុម មានអ្នកគ្រប់គ្រង់ មានលក្ខន្តិកៈ...
- ការដាក់ទុនចូលរួម(១០០ ០០០រៀល/១ហ៊ុន)
- មានម៉ាស៊ីន ២៤ សេស ២គ្រឿង ត្បាល់ ២គ្រឿង ឃ្លាំងស្តុកសម្ភារ១ និងសម្ភារមួយចំនួនទៀត
- បច្ចេកទេស ( រូបមន្តផ្សំ )
- អ្នកជំនាញផ្នែកពេទ្យសត្វ ចំនួន ១០ នាក់
- វត្ថុធាតុដើមសម្រាប់ផ្សំ មាន ១១ មុខរួមមាន ៖ ពោត កន្ទក់ សណ្តែកបាយ សណ្តែកសៀង ដំឡូងមី គ្រាប់កៅស៊ូ ត្រី ក្បាលបង្គា ឆ្អឹង សំបកខ្ចៅខ្យង ប្រេម៉ិច.....

ត្រី និងសណ្តែកសៀង ជាប្រភពប្រូតេអ៊ីន





ដំឡូងមី ពោតក្រហម





កន្ទុកសណ្តែកបាយ



កន្ទុកស្រូវ



ប្រេម៉ិច



## គុណសម្បត្តិ នៃការផ្តល់ចំណីផ្សំ

ការរៀបចំចំណីបានសមស្របតាមលក្ខណៈបច្ចេកទេស យើងទទួលបាន ៖

- សារធាតុចិញ្ចឹមគ្រប់គ្រាន់
- ចំណីមានគុណភាពល្អ ចិញ្ចឹមរយៈពេលខ្លី
- ការកាត់បន្ថយចំណាយ

- គុណភាពសាច់ល្អ
- ទិន្នផលខ្ពស់

## សារធាតុចិញ្ចឹម ឬអាហាររូបត្ថម្ភ

- សារធាតុចិញ្ចឹមសម្រាប់ជ្រូកចែកជា ៣
  - ១- អាហារប្រូតេអ៊ីន=ជាតិសាច់
  - ២- អាហារថាមពល
  - ៣- វីតាមីន និងសារធាតុខនិជ









## កម្រិតប្រូតេអ៊ីនសមស្របសម្រាប់ជ្រូក

| ប្រភេទជ្រូក | កម្រិតប្រូតេអ៊ីន |
|---|---|
| កូនជ្រូក | ២០ % - ២២ % |
| ជ្រូកសាច់ | ១៦-១៨ |
| ជ្រូកសាច់ | ១៥ % - ១៦ % |
| ជ្រូកមេផើម | ១៥ % |
| ជ្រូកមេកើតកូន | ១៤ % |





### តារាងបង្ហាញពីសារធាតុចិញ្ចឹមនៅក្នុងប្រភេទចំណីមួយចំនួន

| ល | ប្រភេទចំណី | ប្រូតេអ៊ីន(%) |
|---|---|---|
| ០១ | សណ្តែកបាយ | ២៦,៦០ |
| ០២ | សណ្តែកសៀង | ៣៣,២០ |
| ០៣ | គ្រាប់ពោត | ១០,៤០ |
| ០៤ | កន្ទក់លេខ ១ | ១២,០០ |
| ០៥ | ចុងអង្ករ | ៨,០០ |
| ០៦ | ម្សៅត្រី-ត្រីទឹកប្រៃ | ៥៦,០០ |
| ០៧ | ម្សៅត្រី-ត្រីទឹកសាប | ៤៨,១៩ |



### ផែនការផលិតចំណីរបស់សមាគមន៍

ដើម្បីបំពេញតម្រូវការទីផ្សារ សហគមន៍បានបោះពុម្ពសំបកបាវ វិចខ្ចប់ចំណីឱ្យ បានត្រឹមត្រូវ ពង្រីកឃ្លាំងស្តុក ពង្រីកទីផ្សារ ពង្រឹងបច្ចេកទេស និងបទពិសោធន៍

### ប្រសិទ្ធភាពសេដ្ឋកិច្ច

- ចំណីកែច្នៃ
  - ជ្រូក ១ក្បាលស៊ីអស់ ៣៥០ គ.ក្រ
  - ចំណាយអស់ ៥២៥,០០០ រៀល
  - រយៈពេលចិញ្ចឹម ៤ ខែកន្លះ
  - ទម្ងន់ ៩០ គ.ក្រ
  - សាច់មានគុណខ្ពស់ល្អ (ក្រហម)
- ចំណីក្រុមហ៊ុន
  - ជ្រូក ១ក្បាលស៊ីអស់ ៣០០ គ.ក្រ
  - ចំណាយអស់ ៧៥០,០០០ រៀល
  - រយៈពេលចិញ្ចឹម ៤ ខែ
  - ទម្ងន់ ៩០ គ.ក្រ
  - សាច់មានគុណល្អ។

### សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖


- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម៖
  អាសយដ្ឋាន ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ
  - ទូរស័ព្ទលេខ : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥
  - ទូរសារលេខ : (៨៥៥)២៣ ២១០ ៩៤៨
  - Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - Department of Agricultural Extension
  - គេហទំព័រ : http://www.maff.gov.kh
- លោក **សឿន ធីរ:** ជាប្រធានសមាគមផលិតចំណីសត្វ នៅភូមិកន្សោមខ្លែង ឃុំជំរះពេន ស្រុកសំរោង ខេត្ត តាកែវ។
  តាមអាសយដ្ឋាន ភូមិបឹងព្រាវ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង។